**ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន (EJC)**
**កិច្ចប្រជុំ #5**
**ថ្ងៃពុធ 9 វិច្ឆិកា 2022**
**ម៉ោង 6:00 ល្ងាច**
**<u>កំណត់ហេតុកិច្ចប្រជុំ</u>**

កន្លែងកិច្ចប្រជុំ៖ ហ្សូមវិបប៊ីណា (Zoom webinar)
ឯកសារកិច្ចប្រជុំ៖ របៀបវារៈ, ស្លាយ, កំណត់ហេតុប្រជុំ (10/27/2022)

**សមាជិកក្រុមប្រឹក្សាមានវត្តមាន៖**

- Kalila Barnett
- Madeline Fraser Cook
- Melissa Ferretti
- Cheryll Holley
- Caroline Hon
- Namrita Kapur
- Lydia Lowe
- Marcos Luna
- Patricia Spence
- Ari Zorn

**បុគ្គលិក EOEAA មានវត្តមាន៖** Rishi Reddi, Vallery Cardoso, Carline Lemoine (ការិយាល័យ EJ Office)

ចាប់ផ្តើមនៅម៉ោង 6:00 ល្ងាច

**សូមស្វាគមន៍ និងទិដ្ឋភាពទូទៅនៃការរៀបចំផែនការនិងការអនុវត្តនៅកិច្ចប្រជុំ**
Rishi Reddi ប្រធាន EJC និងនាយក EJ នៅ EEA បានណែនាំខ្លួនលោកស្រី និងនាយករង Vallery Cardoso និង Carline Lemoine។ Rishi បានកត់សម្គាល់ភាពអាចមានអ្នកបកប្រែភាសា។ លោកស្រីបានពិនិត្យមើលឡើងវិញត្រួសៗអំពីការរៀបចំផែនការនិងការអនុវត្តនៅកិច្ចប្រជុំ។

**ហៅឈ្មោះអ្នកចូលរួមបើមានការយល់ព្រម; ការអនុម័តលើកំណត់ហេតុកិច្ចប្រជុំមុន**
Rishi បានស្នើសុំសមាជិកក្រុមប្រឹក្សាដាក់ឈ្មោះរបស់ពួកគេនៅក្នុងការជជែកសម្រាប់កំណត់ត្រា។ លោកស្រីបានបង្ហាញរបៀបវារៈ ហើយសួរថាតើ សមាជិកក្រុមប្រឹក្សាមានបញ្ហាបន្ថែមដែលពួកគេចង់បន្ថែមឬទេ។ មិនមានការបន្ថែមទេ។

Rishi បានហៅឈ្មោះអ្នកចូលរួមដើម្បីបញ្ជាក់កូរ៉ុម។ បញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាដែលមានវត្តមានត្រូវបានរាយបញ្ជីខាងលើ ដែលស្ថិតក្រោម "សមាជិកក្រុមប្រឹក្សាដែលមានវត្តមាន"។

Rishi បានសួរ EJC ថាតើពួកគេមានការបន្ថែមណាមួយលើកំណត់ហេតុកិច្ចប្រជុំឬទេ។ Marcos Luna បានផ្តល់មតិយោបល់ថាមតិយោបល់និងសំណួរនានាដែលបានផ្ញើទៅក្នុងប្រអប់ជជែកនៅអំឡុងពេលកិច្ចប្រជុំ EJC ចុងក្រោយ មិនបានរាប់បញ្ចូលក្នុងកំណត់ហេតុនោះទេ។ Vallery Cardoso, បុគ្គលិក EOEEA បានឆ្លើយតបថា នៅពេលសំណួរនានាដែលបានឆ្លើយតបនោះ នឹងត្រូវដាក់ផ្សព្វផ្សាយតាមវិបសាយ mass.gov. Rishi បានផ្តល់មតិយោបល់ថា ដំណើរការឆ្ពោះទៅមុខនោះយើងត្រូវបញ្ចូលសំណួរនិងមតិយោបល់នានានៅក្នុងកំណត់ហេតុ ទោះបីជាមិនមានចម្លើយទាំងអស់ក៏ដោយ។ Marcos បានស្នើសុំថាមតិសាធារណជននិងសំណួរនានាត្រូវបញ្ចូលក្នុងកំណត់ហេតុ។ Namrita បានស្នើសុំផងដែរ។ Rishi បានហៅសមាជិកក្រុមប្រឹក្សាឱ្យមានការបោះឆ្នោតដោយហៅឈ្មោះអ្នកចូលរួមបើមានការយល់ព្រម។ សមាជិកក្រុមប្រឹក្សាទាំងអស់ដែលមានវត្តមានបានបោះឆ្នោតយល់ព្រម ដើម្បីអនុម័តលើកំណត់ហេតុកិច្ចប្រជុំ។ កំណត់ហេតុប្រជុំបានអនុម័ត។

**សេចក្តីប្រកាស**
Rishi បានប្រកាសថាសេចក្តីព្រាងនៃការវាយតម្លៃការប្រែប្រួលអាកាសធាតុរបស់ EEA អាចមានសម្រាប់មតិយោបល់សាធារណជន។ មតិយោបល់នឹងត្រូវទទួលយកតាមទម្រង់នេះ (https://www.mass.gov/info-details/ma-climate-change-assessment.) រហូតដល់ថ្ងៃទី 11/16.

**ការធ្វើបច្ចុប្បន្នភាពផែនទី EJ ដោយមានទិន្នន័យជំរឿនសហរដ្ឋអាមេរិកថ្មីៗបំផុត (US Census Data)**
Rishi បានផ្តល់ព័ត៌មានលើការធ្វើបច្ចុប្បន្នភាពផែនទី EJ។ បន្ទាប់មកលោកស្រីបានស្នើសុំ ដើម្បីទទួលយកការធ្វើបច្ចុប្បន្នភាពផែនទី។ Namrita Kapur បានស្នើសុំ, Ari Zorn បានស្នើសុំផងដែរ។ Caroline Hon បានសួរថាតើ EJC អាចទទួលបានទិន្នន័យបន្ថែមអំពីអ្វីដែលមានការផ្លាស់ប្តូរ ឬទេ។ Lydia Lowe បានផ្តល់មតិយោបល់ថានាងមានសំណួរអំពីទិន្នន័យនិងសហគមន៍នានាដែលលែងត្រូវបានកំណត់ថាជា EJ ទៀតទេ។ Rishi បានផ្តល់មតិយោបល់ថា យើងត្រូវធ្វើបច្ចុប្បន្នភាពផែនទី ដើម្បីបុរាកដថាផែនទីនៅថ្មីដដែល។ លោកស្រីបានផ្តល់មតិយោបល់ថាការងាររបស់ EJC គឺដើម្បីពិនិត្យមើលឡើងវិញនូវនិយមន័យ ដូច្នេះ EJC នឹងពិនិត្យមើលផែនទីទាំងនេះ ដូចដែលមើលតាមយមន័យផងដែរ។ ការបោះឆ្នោតនេះ ដើម្បីធ្វើបច្ចុប្បន្នភាពផែនទីដែលនិយាយថា EJC កំពុងបន្តធ្វើបច្ចុប្បន្នភាពជាមួយរដ្ឋាភិបាលសហព័ន្ធ។ យើងនឹងត្រឡប់មកវិញសម្រាប់ការវិភាគលម្អិត។ Rishi បានហៅការបោះឆ្នោតដោយហៅឈ្មោះអ្នកចូលរួមបើមានការយល់ព្រម។ សមាជិកក្រុមប្រឹក្សាបច្ចុប្បន្ន ទាំងអស់ បានបោះឆ្នោតយល់ព្រម ដើម្បីទទួលយកការធ្វើបច្ចុប្បន្នភាពផែនទី។

**យុទ្ធសាស្ត្រ EEA EJ (EEA EJ Strategy)៖ ទិដ្ឋភាពទូទៅ បើកដំណើរការជាផ្លូវការ មតិយោបល់សាធារណជន**

Rishi បានផ្តល់ជូនទិដ្ឋភាពទូទៅនៃការអភិវឌ្ឍន៍យុទ្ធសាស្ត្រ (EJ Strategy) និងការកំណត់ពេលវេលាសម្រាប់ការបើកដំណើរការជាផ្លូវការ និងការផ្តល់មតិយោបល់សាធារណជន។ សមាជិក EJC បានផ្តល់មតិយោបល់ដូចខាងក្រោម៖

- **Kalila**: ការបញ្ជាក់អំពីរបៀបដែលការពិភាក្សាអំពីយុទ្ធសាស្ត្រសមស្របនឹងការងារដែល EJC កំពុងអនុវត្ត។ Rishi បានឆ្លើយតបថា វាជាឯកសារណែនាំមួយសម្រាប់ទីភ្នាក់ងារ EEA។
- **Namrita**: ចង់មើលផ្នែកនិយមន័យនៃឯកសារ។
- **Rishi**: សង្ឃឹមថារបៀបវារៈនាពេលអនាគតអាចកំណត់ពេលវេលាដើម្បីពិភាក្សាតាមរយៈឯកសារ ហើយ EJC អាចត្រូវបានរៀបចំ ត្រៀមខ្លួនដើម្បីពិភាក្សាអំពីរឿងនេះ។
- **Caroline**: តើអាចធ្វើបទបង្ហាញសង្ខេបឯកសារបានឬទេ? ចំណុចនេះ អាចមានប្រយោជន៍សម្រាប់ការពិភាក្សាប្រមូលព័ត៌មានអំពី បទពិសោធន៍។ ពិតជាល្អណាស់ដែលមានចំណុចបញ្ជាក់សំខាន់ៗអំពីប្រធានបទ។ ប្រហែលជាបញ្ជូនសំណួរជាមុន។
- **Rishi**: យុទ្ធសាស្ត្រគឺជាឯកសារព្រាង ហើយបើកចំហចំពោះតម្រូវការរបស់ EJC ដែលមានរយៈពេលយ៉ាងតិចពីរបីខែ។ គំនិតបន្ថែមណាមួយអាចបញ្ជូនទៅ Vallery។

**ការពិភាក្សា៖ តើនរណា/អ្វីដែលបាត់បង់ពីនិយមន័យនៃប្រជាពលជន EJ នាពេលបច្ចុប្បន្ន? (បន្តពីកិច្ចប្រជុំលើកទី #4 ថ្ងៃទី 27 ខែតុលា ឆ្នាំ 2022)**

Rishi បានគូសបញ្ជាក់ថាការិយាល័យ EJ នឹងត្រូវដាក់បញ្ចូលគ្នានូវឯកសារមតិយោបល់ ដើម្បីជួយគិតតាមរយៈប្រធានបទនានាដែលត្រូវការ ការពិភាក្សាបន្ថែមទៀត។ លោកស្រីបានលើកឡើងថាលោកស្រីចង់ពិភាក្សាអំពីដំណើរការដែល EJC នឹងដោះស្រាយលើប្រធានបទ។ លោកស្រីបានសួរពីរបៀបដែលយើងអនុវត្តនិយមន័យ EJ នៅខណៈពេលដែលចំនួនប្រជាជន ឬក្រុមការងារភូមិសាស្ត្រត្រូវបានកំណត់។ Rishi បានអានបញ្ជីបញ្ហាដែលកំណត់ដោយ EJC ពីកិច្ចប្រជុំថ្ងៃទី 27 ខែតុលា ឆ្នាំ 2022។ ចំណុចខាងក្រោមនេះ ជាមតិយោបល់សង្ខេបរបស់ EJC។

- **Ari**: កម្រិតភាពក្រីក្រអាចរួមបញ្ចូលកាន់តែច្រើនចំពោះប្រជាពលរដ្ឋស្បែកសដែលមានប្រាក់ចំណូលទាប។
- **Melissa**: ពាក្យថាជនជាតិភាគតិច គឺជាការលំពិបាកចំពោះជនជាតិដើមភាគតិច។ យើងជាអង្គភាពនយោបាយដែលមានសិទ្ធិ។
- **Lydia**: ការព្រួយបារម្ភថាបើភាគរយនឹងដាក់ចូលសហគមន៍ EJ តូចៗ។ រួមទាំងអ្នកដែលមានបញ្ហាការផ្លាស់ទីលំនៅនិងការផ្លាស់ទីលំនៅអ្នកមានទ្រព្យទៅក្នុងទីក្រុងក្រីក្រ។ ចំណុចនេះ អាចមានន័យថាសហគមន៍ទាំងនេះមិនទទួលបានលក្ខខណ្ឌល្អប្រសើរជាងមុនទេ ប៉ុន្តែត្រូវបានគេបណ្តេញចេញ។
- **Rishi**: មានជាតុផ្សេងៗ និយមន័យ ដើម្បីអនុញ្ញាតឱ្យលេខាធិការ EEA កំណត់ស្ថានភាព EJ ឬសម្រាប់វាត្រូវបានដកចេញ។ យើងមិនទាន់មានការអនុវត្តច្បាប់ទាំងនោះនៅឡើយទេ។
- **Madeline**: ហាក់ដូចជាការផ្តល់ជូននេះចាប់ផ្តើមដោះស្រាយសហគមន៍ជនបទនិងអត្រាភាពក្រីក្រកាន់តែច្រើន។ មិនអាចនិយាយថាតើវានឹងដោះស្រាយក្រុមរងតូចៗទាំងនេះទេ ប៉ុន្តែប្រហែលជាវាអាចមាន?
- **Rishi**: តើភាគរយភាពក្រីក្រកំណត់អ្វីដែលកំពុងកើតឡើងនៅភាគខាងលិចឬទេ?
- **Cheryll**: ហេតុអ្វីបានជានិយមន័យ EJ ជាតំបន់ឬកន្លែង? ហេតុអ្វីបានជាវាមិនអាចជាប្រជាជន និង
- **Kalila**: តើមានឧទាហរណ៍អំពីអ្វីដែល Cheryll កំពុងគិតអំពីនោះ? ប្រហែលជាលក្ខណៈវិនិច្ឆ័យសុខភាពសាធារណៈមួយចំនួន ដូចជាជាតិសាសន៍ និងប្រាក់ចំណូល។
- **Rishi**: តើយើងអាចនិយាយបន្ថែមអំពីវិធីដែលយើងកំណត់បន្ទុក EJ និងទំនាក់ទំនងរបស់ខ្លួនចំពោះកន្លែងបានឬទេ? តើសហគមន៍ជនជាតិដើមភាគតិចដែលទទួលរងភាពអយុត្តិធម៌បរិស្ថានដែលអាចកំណត់និយមន័យតាមរយៈបន្ទុកបរិស្ថានយ៉ាងដូចម្តេច?
- **Melissa**: កសិដ្ឋានស្ពូឡាកំពុងដកយកដីដែលមានតាំងពីដើម ដែលកុលសម្ព័ន្ធមិនអាចចូលប្រើបានទៀតទេ។ ការចូលទៅកាន់ផ្លូវទឹក។ យើងទទួលរងទុក្ខពីព្រោះយើងមិនអាចរស់នៅដោយទទួលនៅដីនោះបានទេ។
- **Rishi**: ពីទីកន្លែងគោលនយោបាយ ប្រជាជនជនជាតិដើមភាគតិចអាចរស់នៅទីតាំងជាក់លាក់មួយ ប៉ុន្តែដីដែលចាំបាច់សម្រាប់របៀបរស់នៅកំពុងត្រូវបានបាត់បង់។
- **Melissa**: ដីត្រូវបានគេយករួចទៅហើយ។ តាមបច្ចេកទេសយើងមិនត្រូវការការអនុញ្ញាត ដើម្បីបន្តនិយាយអំពីអចលនទ្រព្យនោះទេ។ របៀបដែលទីជម្រកកំពុងទទួលរងឥទ្ធិពលដែលមានផលប៉ះពាល់ដល់ប្រជាជនជនជាតិដើមភាគតិច
- **Melissa**: វាពិតជានិយាយអំពីធនធាន។
- **Rishi**: ជំហានដំបូងសម្រាប់ប្រជាពលរដ្ឋនៅក្នុងក្រុមនេះ គឺថាយើងត្រូវធ្វើឱ្យកាន់តែស៊ាំទៅនឹងការបញ្ជាក់អំពីតំបន់ភូមិសាស្ត្រ។ ដែលអាចរារាំងការពិភាក្សានេះ។ តើយើងអាចទទួលបានការពិភាក្សានេះដោយរបៀបណា?
- **Cheryll**: MA មានកាតព្វកិច្ចចំពោះអ្នកដែលពួកគេមានសន្ធិសញ្ញា កុលសម្ព័ន្ធត្រូវបានបន្ថែមទៅនឹងនិយមន័យ EJ។ សន្ធិសញ្ញានៅតែរក្សានៅដដែល។
- **Rishi**: ជនជាតិដើមរួមបញ្ចូលនៅក្នុងនិយមន័យជនជាតិភាគតិច។ ប៉ុន្តែបានផ្តល់ការផ្តល់មតិយោបល់របស់ Melissa អំពីកុលសម្ព័ន្ធជាអង្គភាពនយោបាយ ដែលយើងត្រូវធ្វើការកែតម្រូវដោយផ្អែកលើមតិយោបល់របស់លោកស្រី។
- **Cheryll**: កុលសម្ព័ន្ធខ្លះ មានទំនាក់ទំនងពិសេស និងអធិបតេយ្យភាពជាមួយរដ្ឋ។ បន្ទាប់មកមានសមាជិកកុលសម្ព័ន្ធដែលអាចសមស្របនឹងនិយមន័យជនជាតិភាគតិច។ សម្រាប់ការបញ្ជាក់តំបន់នានាដែលមានផែនទីជាច្រើន ដែលអាចជួយចំណុចនោះបាន។
- Rishi បានស្នើសុំឱ្យអ្នកស្ម័គ្រចិត្តបង្កើតបញ្ជីមួយ ដើម្បីធ្វើសង្ខេបបញ្ហាទាំងនេះ។ Melissa និង Cheryll បានស្ម័គ្រចិត្ត។
- Rishi បាននិយាយអំពីបំណងប្រាថ្នារបស់លោកស្រី ដើម្បីពិភាក្សាអំពីបញ្ហានៅភាគខាងលិច។ បានផ្តល់មតិយោបល់ថាអ្នកដែលមានប្រាក់ចំណូលទាបនៅក្នុងក្រុមតូចៗនៃពណ៌សម្បុរទាំងអស់ មិនត្រូវបានរាប់បញ្ចូលនោះទេ។ បាននិយាយអំពីសមត្ថភាពរបស់លេខាធិការក្នុងការរួមបញ្ចូលចំនួនប្រជាជននៅតាមក្រុមការងារភូមិសាស្ត្ររង។ Ari

បានបញ្ជាក់ថាសហគមន៍មួយចំនួននៅជនបទ មានការលាយឡំគ្នាជាមួយអ្នកមាននិងអ្នកក្រយ៉ាងច្រើន។ ការផ្លាស់ទីលំនៅអ្នកមានទ្រព្យទៅក្នុងទីក្រុងក្រីក្រ ក៏ជាបញ្ហាធំផងដែរ។

- **Melissa**: ការផ្លាស់ទីលំនៅអ្នកមានទ្រព្យទៅក្នុងទីក្រុងក្រីក្រ គឺជាបញ្ហាមួយនៅ Cape។ Plymouth ត្រូវបានគេចាត់ទុកថាជាសហគមន៍ EJ ផងដែរ។
- **Cheryll**: និយមន័យ EJ មានទំនាក់ទំនងទៅនឹងគ្រោះថ្នាក់បរិស្ថាន។ អ្នកមានអាចឆ្លើយតបទៅនឹងគ្រោះថ្នាក់បានលឿនជាងមុន ហើយអ្នកក្រត្រូវការការការពារផងដែរ ដោយមិនគិតពីចំនួនពួកគេឡើយ។
- **Rishi**: ដោយមើលឃើញបញ្ហាជាច្រើនជុំវិញប្រាក់ចំណូល ជាពិសេសនៅតំបន់ជនបទ។ តើមានអ្វីមួយអំពីលក្ខណៈវិនិច្ឆ័យប្រាក់ចំណូល ដែលធានាឱ្យមានការវិភាគស៊ីលម្អិតឬទេ?
- **Lydia**: នៅ Chinatown មានផ្ទះអ្នកមាន និងអ្នកដែលមានប្រាក់ចំណូលទាប ហើយមានស្ថានភាពរញ៉េរញ៉ៃជាមួយប្រជាពលរដ្ឋ។ ឥទ្ធិពលបន្ថែមលើគ្នាជាចំណុចសំខាន់។
- **Rishi**: ការណ៍នេះកំពុងបង្កើនបញ្ហាជុំវិញអ្វីដែលយើងកំពុងមើលឃើញនៅតំបន់ដែលមានប្រាក់ចំណូលទាបទាំងនេះ។
- **Marcos**: និយមន័យមិនបានកំណត់ដើម្បីគិតអំពីចំនួនប្រជាពលរដ្ឋនោះទេ ប៉ុន្តែគិតអំពីកន្លែងដែលមនុស្សរស់នៅ។ យុទ្ធសាស្រ្ត EEA ត្រូវគិតតាមរយៈអ្វីដែលយុទ្ធសាស្រ្តកំពុងស្នើសុំអនុវត្ត។ ការគិតអំពីការអនុវត្តនេះ អាចមានប្រយោជន៍។
- **Rishi**: មើលលក្ខណៈវិនិច្ឆ័យជនជាតិភាគតិច និងប្រាក់ចំណូលនិងប្រាក់ចំណូល ដែលទាំងពីរនេះមានន័យខុសគ្នាជាច្រើន។
- **Lydia**: យល់ច្រឡំអំពីរបៀបដែលនិយមន័យនិយាយអំពីបន្ទុក និងអត្ថប្រយោជន៍។ ចំណុចរួមទាំងពីរនេះ មានសារៈសំខាន់ខ្លាំងណាស់ចំពោះការពិភាក្សានេះ។
- **Rishi**: បញ្ហាធំពីរគឺជនជាតិដើមភាគតិច និងប្រាក់ចំណូលនៅជនបទ និងទីក្រុង។ តើយើងត្រូវបង្កើតបញ្ជីបញ្ហាដែលបន្ទាន់ឬទេ? តើយើងត្រូវមានការសន្ទនាផ្តោតសំខាន់លើបញ្ហាជាក់លាក់បន្ថែមទៀតឬទេ?
- **Marcos**: មានបញ្ជីឈ្មោះប្រធានបទដែលដំណើរការ ដែលលើកមកនិយាយ។ ដំណោះស្រាយរបស់អនុគណៈកម្មការ អាចជាមធ្យោបាយដ៏ល្អមួយមានដំណើរការឆ្ពោះទៅមុខ។
- **Rishi**: យើងនឹងធ្វើការលើបញ្ជី និងបង្កើតអនុគណៈកម្មការ។ នៅក្នុងក្រុមការងារ EJC នឹងត្រូវការចាំបាច់ត្រឡប់មកវិញជាមួយនឹងសំណើជាក់ស្តែង។

**សំណួរ/មតិយោបល់ពីសាធារណជន**

Rishi បានផ្តល់ជូនឱកាសសំណួរពីសាធារណជន។

Vallery Cardoso អានសំណួរពីប្រអប់សំណួរនិងចម្លើយ Q&A។ សំណួរនិងចម្លើយទាំងនេះ បានរួមបញ្ចូលដូចខាងក្រោម។

| # | សំណួរ | ឈ្មោះអ្នកសួរ | ចម្លើយ |
|---|---|---|---|
| 1 | សូមលោកអ្នកនិយាយម្តងទៀតអំពីការកើនឡើងចំនួនប្រជាជន EJ នៅក្នុងផែនទីថ្មីទាំងនេះឬទេ? ទាំងការកើនឡើងភាគរយ និងចំនួនប្រជាជន? | អ្នកចូលរួមអនាមិក | ការរាប់បញ្ចូលក្រុមការងារភូមិសាស្ត្រ EJblock កំពុងកើនឡើងពី 2,316 (46%) ទៅ 2,604 (51%) ក្នុងចំណោម 4985 នៅទូទាំងរដ្ឋ។<br><br>ចំនួនមនុស្សដែលរស់នៅក្នុងក្រុមការងារភូមិសាស្ត្រ EJ កំពុងកើនឡើងពី 3,100,468 ទៅ 3,487,681 (+12.5%)<br><br>ចំនួនទីក្រុងដែលមានក្រុមការងារភូមិសាស្ត្រ EJ កំពុងថយចុះពី 188 ទៅ 187<br><br>ចំនួនទីក្រុង 19 លែងមានក្រុមការងារភូមិសាស្ត្រដែលមានលក្ខណៈវិនិច្ឆ័យ EJ ទៀតហើយ<br><br>ចំនួនទីក្រុង 18 ដែលឥឡូវនេះមានក្រុមការងារភូមិសាស្ត្រយ៉ាងតិចមួយដែលបំពេញតាមលក្ខណៈវិនិច្ឆ័យ EJ |
| 2 | សួស្តី! ខ្ញុំបានខកខានកិច្ចប្រជុំចុងក្រោយ ដូច្នេះខ្ញុំអាចប្រើការបំភ្លឺខ្លះៗលើការពិភាក្សាដែលកំពុងបន្តដំណើរការ អំពីនិយមន័យនៃ EJ។ ការយល់ដឹងរបស់ខ្ញុំគឺថាវាកំណត់រួចហើយនៅក្នុងច្បាប់ទាំងសហព័ន្ធនិងនៅក្នុង Mass។ តើក្រុមនេះកំពុងគិតពិចារណាលើការស្នើសុំការផ្លាស់ប្តូរនៅក្នុងច្បាប់នេះ ឬតើមានគោលបំណងផ្សេងទៀត | Betsy Sowers | និយមន័យ EJ បានកំណត់នៅក្នុងច្បាប់ ប៉ុន្តែច្បាប់នេះក៏មានបទប្បញ្ញត្តិថា "ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថានត្រូវធ្វើការវិភាគយ៉ាងទូលំទូលាយ ... ហើយរៀងរាល់ឆ្នាំទី 5 បន្ទាប់ពីនោះ ដើម្បីធានាឱ្យនិយមន័យអំពីចំនួនប្រជាជនយុត្តិធម៌បរិស្ថានសម្រេចបានគោលបំណងនៃគោលការណ៍ យុត្តិធម៌បរិស្ថាន ដោយអនុលោមតាមនិយមន័យនៃចំនួនប្រជាជនយុត្តិធម៌បរិស្ថាន |

| | | | |
|---|---|---|---|
| | សម្រាប់ការសន្ទនាអំពីអត្ថន័យនៃ EJ ដែលខ្ញុំបាន ខកខានឬទេ? សូមអរគុណ! | | និងគោលការណ៍យុត្តិធម៌បរិស្ថានដែលមាននៅផ្នែក 62" |
| 3 | សូមអរគុណលោកអ្នក!! | អ្នកចូលរួមអនាមិក | សូមស្វាគមន៍លោកអ្នក! |
| 4 | សូមអរគុណ Vallery! | Betsy Sowers | សូមស្វាគមន៍លោកអ្នក! |
| 5 | តើវាអាចដឹងថាមានសមាជិកដែលមិនមែនជាក្រុមប្រឹក្សាភិបាលប៉ុន្មាននាក់ដែលកំពុងចូលរួមការហៅនេះ? | Laura Spark | បាទ/ចាស់<br>បច្ចុប្បន្នមានការចូលរួមពីសមាជិកនៃសាធារណជនចំនួន 37 នាក់ |
| 6 | សូមអរគុណលោកអ្នក! | Laura Spark | សូមស្វាគមន៍លោកអ្នក! |
| 7 | តើលោកអ្នកអាចចែករំលែកកាលបរិច្ឆេទសម្រាប់<br>កិច្ចប្រជុំ និងការពិភាក្សាប្រមូលព័ត៌មានអំពីបទពិសោធន៍នាពេលខាងមុខបានឬទេ? | Danielle Dolan | ព័ត៌មានអំពី<br>ការពិភាក្សាប្រមូលព័ត៌មានអំពីបទពិសោធន៍នឹងផ្សព្វផ្សាយតាមតំណភ្ជាប់ខាងក្រោម៖<br>https://www.mass.gov/info-details/eeas-draft-environmental-justice-ej-strategy.<br>កាលបរិច្ឆេទអាចរកបានតាមស្លាយ 17។<br>ស្លាយមានតំណភ្ជាប់នៅទីនេះ៖<br>https://www.mass.gov/event/november-9-2022-meeting-of-the-environmental-justice-council-ejc-2022-11-09t180000-0500-2022-11-09t200000-0500 |
| 8 | ក្នុងនាមជាប្រជាពលរដ្ឋអាយុ 80 ឆ្នាំរស់នៅ Cape Cod<br>វាពិបាកចូលរួមក្នុងកិច្ចប្រជុំជួបដោយផ្ទាល់នៅបូស្តុន Boston<br>ឬបញ្ជូនមតិយោបល់ជាលាយលក្ខណ៍អក្សរនៅត្រឹមថ្ងៃទី 13 ខែមករា<br>បន្ទាប់ពីកិច្ចប្រជុំតាម<br>អនឡាញដែលមានរយៈពេលពីរបីថ្ងៃមុនថ្ងៃផុតកំណត់។<br>មនុស្សចាស់ជាច្រើននាក់មានបញ្ហាប្រឈមផ្នែកបច្ចេកទេសក្នុងការចូលរួមសវនាការសាធារណៈតាម<br>ហ្សូម ZOOM។<br>ខ្ញុំមានរឿងនេះនៅកិច្ចប្រជុំក្រុមប្រឹក្សា EPA EJ ដែលខ្ញុំត្រូវហៅទូរស័ព្ទផ្នែកការផ្តល់មតិយោបល់សាធារណជនរបស់ខ្ញុំរយៈពេល 3 នាទី<br>ដោយសារជម្រើសបិទសម្លេងមិនដំណើរការ។ | David Dow | សូមអគុណលោកអ្នកចំពោះមតិយោបល់របស់អ្នក។<br>ខ្ញុំយល់ពីការព្រួយបារម្ភរបស់អ្នក<br>និងតម្រូវការចំពោះជម្រើសនិងទីកន្លែងកិច្ចប្រជុំផ្សេងៗ។<br>យើងចង់ធ្វើឱ្យប្រាកដថាកិច្ចប្រជុំរបស់យើងអាចចូលដំណើរការបានតាមដែលអាចធ្វើទៅបាន។<br>ខ្ញុំនឹងយករឿងនេះមកជូនក្រុមការងារខ្ញុំវិញ<br>ដើម្បីពិភាក្សា។ |
| 9 | សូមអរគុណលោកអ្នក | Danielle Dolan | |

| | | | |
|---|---|---|---|
| 10 | ខ្ញុំបានប្រាស្រ័យទាក់ទងជាមួយមនុស្សចាស់ដែលរស់នៅអាផាតមេនលំនៅដ្ឋានមនុស្សវ័យចំណាស់នៅ Falmouth ដែលបង់ប្រាក់ 30% នៃប្រាក់ចំណូល របស់ពួកគេក្នុងការជួលផ្ទះ។ អ្នករស់នៅទាំងនេះ ភាគច្រើនជាជនជាតិស្បែកស ឬជនជាតិឡាទីន ដែលប្រាក់ចំណូលរបស់ពួកគេអាស្រ័យលើការធានារ៉ាប់រងសង្គមកិច្ចដែលអាចតិចជាង $1500 ក្នុងមួយខែ ដែលមានន័យថាថ្លៃសជួលផ្ទះ $450 ក្នុងមួយខែ។ នៅ Hyannis អាផាតមិនដែលមានតម្លៃសមរម្យមានចាប់ពី $1500-2000 ក្នុងមួយខែ ដែលកម្មករក្រីក្រនៅក្នុងឧស្សាហកម្មសេវាកម្មមិនអាចអាចបង់ប្រាក់បានទេ។ ដូច្នេះនិយមន័យ EJ ត្រូវរួមបញ្ចូលការចំណាយលើ ការរស់នៅទាក់ទងនឹងប្រាក់ចំណូលដែលបុគ្គលទទួលបាន។ ខ្ញុំប្រាកដថាបញ្ហានេះ កាន់តែអាក្រក់នៅបូស្តុន Boston ជាកន្លែងដែលមានជនជាតិភាគតិចរស់នៅច្រើន។ | David Dow | |
| 11 | ខ្ញុំគិតថាវាពាក់ព័ន្ធនឹងការបំពុលបរិស្ថានមិនត្រឹមតែចំពោះខ្យល់ ទឹក ឬដីទេ ប៉ុន្តែអាហារដែលគេដាំដុះនិងប្រើប្រាស់។ | អ្នកចូលរួមអនាមិក | |
| 12 | កុលសម្ព័ន្ធ Mashpee Wampanoag បរបាញ់សត្វ និងនេសាទនៅលើដីប្រពៃណីដែលមានការបំពុលដោយសារធាតុគីមីពុល (PFAS; មេទីល បារ៉ត (methyl mercury); ស៊ីណាអូបាក់តេរី (cynaobacterial toxins) ជាដើម។ វិទ្យាស្ថានសៃឡេន ស្ព្រីង (Silent Spring Institute) បានបង្កើតគម្រោង EJ ជាមួយកុលសម្ព័ន្ធដើម្បីត្រួតពិនិត្យកម្រិតជាតិពុល PFAS ក្នុងអាហារដែលពួកគេទទួលបានដោយ ការបរបាញ់ និងការនេសាទ។ តំបន់ Joint Base Cape Cod គឺជាទីតាំង Superfund នៅមូលដ្ឋានដែលមាន ការបំពុលទឹកផឹក និងផ្ទៃទឹក ត្រីនិងសំបកខ្យង ជាដើម នៅក្នុងស្រះទឹកសាបនៅមូដ្ឋាន (ផ្អែកលើ Ma។ នាយកដ្ឋានស្តង់មតិសុខភាពសាធារណៈសម្រាប់ស្រះទឹក)។ | David Dow | សូមអរគុណលោកអ្នកចំពោះការចែករំលែកព័ត៌មាននេះ។ |
| 13 | សូមទាក់ទងវេជ្ជបណ្ឌិត Dr. Laurel Schaider នៅ SSI សម្រាប់ព័ត៌មានលម្អិត។ | David Dow | |
| 14 | តើលោកអ្នកនឹងធ្វើឱ្យប្រាកដថាអ្នករស់នៅយល់ដឹងអំពីលទ្ធភាពរួមបញ្ចូលជាសហគមន៍ EJ យ៉ាងដូចម្តេច? | Lila Greiner | យើងត្រូវធ្វើការផ្សព្វផ្សាយបន្ថែមទៀតអំពីលទ្ធភាពនេះ។ |
| 15 | ដូចគ្នាផងដែរ និយមន័យនិងផែនទីមិនយកមកគិតពីអតីតកាលទេ។ តំបន់នានាដែលពីមុនមានសហគមន៍ពណ៌សម្បុរច្រើន ឬប្រជាជនមានប្រាក់ចំណូលទាប ឬសហគមន៍ជនជាតិដើមភាគតិច ប៉ុន្តែឥឡូវមាន សហគមន៍ស្បែកស ឬអ្នកមានច្រើននាក់ថែមទៀត។ វាមិនបង្ហាញពីការផ្លាស់ទីលំនៅអ្នកមានទ្រព្យទៅ ក្នុងទីក្រុងក្រីក្រពីអតីតកាល និងអ្នកដែលត្រូវបានបង្ខំឱ្យចាកចេញនោះទេ។ | carrieanne petrik | សូមអគុណលោកអ្នកចំពោះមតិយោបល់របស់អ្នក |

| | | | |
|---|---|---|---|
| | ដែលនៅភាគខាងលិចក៏រាប់បញ្ចូលទាំងកុលសម្ព័ន្ធ ស្តុកប្រ៊ិច មូនស៊ី (Stockbridge Munsee) នៃជនជាតិម៉ូហ៊ីខេន (Mohican) ផងដែរ។ | | |
| 16 | វិលត្រឡប់ទៅផែនទីដែលបានធ្វើបច្ចុប្បន្នភាព តើវានឹងត្រូវបោះពុម្ពផ្សាយនៅពេលណា? | អ្នកចូលរួមអនាមិក | ឯកសារអំពីការធ្វើបច្ចុប្បន្នភាពផែនទីមាននៅលើគេហទំព័រ EJ ។ មានផ្ទាំងថេបមួយសម្រាប់ការបច្ចុប្បន្ន និងផ្ទាំងថេបមួយសម្រាប់សេចក្តីព្រាងផែនទីពីមុន។ ទីភ្នាក់ងារ EEA នីមួយៗនឹងអនុវត្តចំណុចនោះតាមលក្ខណៈផ្ទាល់ខ្លួនរបស់ពួកគេ តាមពេលវេលាដែលសមហេតុផលសម្រាប់កម្មវិធីជាក់លាក់របស់ពួកគេផ្ទាល់។<br>យើងស្នើឱ្យពួកគេអនុវត្តដូច្នេះនៅនៅត្រឹមដើមឆ្នាំ 2023។ |
| 17 | តើលោកអ្នកអាចបញ្ជាក់បានទេថា អ្នករស់នៅទាំងអស់ ឬភាគច្រើននៅក្នុង EJC មានប្រាក់ចំណូលទាប? | អ្នកចូលរួមអនាមិក | ប្រាក់ចំណូលទាបគឺជាលក្ខណៈវិនិច្ឆ័យមួយក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំងបីចំពោះការកំណត់ជាក្រុមការងារ<br>ភូមិសាស្ត្រ EJ (សង្កាត់ជិតខាង) |
| 18 | ក្រុមការងារភូមិសាស្ត្រ | អ្នកចូលរួមអនាមិក | |
| 19 | តើយើងអាចបញ្ជូនមតិយោបល់ ឬគ្រាន់តែសំណួរនានាចំណុចនេះឬទេ? | Danielle Dolan | |
| 20 | សូមអរគុណលោកអ្នក៖ សហគមន៍នានាត្រូវបានកំណត់យ៉ាងទូលំទូលាយជាជាងគ្រាន់តែជាការកំណត់ភូមិសាស្ត្រ; និយមន័យត្រូវរួមបញ្ចូលការចាត់ថ្នាក់ចំនួនប្រជាជន<br>ដែលបានចែកចាយ<br>(ដូចជាជនជាតិដើមភាគតិច<br>ដែលរស់នៅទូទាំងតំបន់ជាច្រើន<br>មិនត្រូវបានផ្តោត នៅក្នុងប្លុកជំរឿន<br>ដូចគ្នានឹងភាពក្រីក្រផងដែរ POCs<br>បានផ្សព្វផ្សាយនៅក្នុងប្លុកដែលមិនមែនជា EJ ជាដើម) | Danielle Dolan | |
| 21 | គិតពិចារណាលើការពង្រីកលើសពីលក្ខណៈវិនិច្ឆ័យដែលមានស្រាប់<br>ដើម្បីរួមបញ្ចូលកត្តាផ្សេងទៀត (ឧទាហរណ៍ សុខភាពសាធារណៈ បន្ទុកការបំពុល បរិស្ថាន ជាដើម) សូមមើលឧទាហរណ៍ CalEnviroScreen ។ | Danielle Dolan | |
| 22 | សូមចងចាំអំពីគោលបំណងនៃនិយមន័យនេះ - ដើម្បីធានាថាការវិនិយោគរបស់រដ្ឋ<br>និងសហព័ន្ធត្រូវបាន<br>ដឹកនាំតម្រង់ឆ្ពោះទៅរកការបម្រើការងារ<br>និងផ្តល់<br>អត្ថប្រយោជន៍ដល់ប្រជាជនដែលមានបន្ទុកលើសលប់ជាប្រវត្តិសាស្ត្រ -<br>ត្រូវការរៀបចំរួមបញ្ចូលតាមដែលអាចធ្វើទៅបាន ដើម្បីសម្រេចបានគោលដៅនោះ។ គម្រោងនិងការវិនិយោគអាចត្រូវបានដោះស្រាយតាមលក្ខខណ្ឌមួយចំនួន<br>មិនចាំបាច់ភ្ជាប់នឹងទីតាំងភូមិសាស្ត្រ<br>និងអាចកំណត់គោលដៅក្រុមប្រជាជនដែលបានផ្សព្វផ្សាយតាមភូមិសាស្ត្រ។<br>ជនជាតិដើមភាគតិច<br>និងអ្នកតំណាងកុលសម្ព័ន្ធត្រូវ<br>បានចាត់ទុកថាជាចំនួនប្រជាជន ឬសហគមន៍ | Danielle Dolan | សូមអគុណលោកអ្នកចំពោះមតិយោបល់របស់អ្នក! |

| | | | |
|---|---|---|---|
| | EJ ដោយមិនគិតពីទីតាំងភូមិសាស្ត្រ។<br><br>ចុងក្រោយនេះ សូមអរគុណ! | | |
| 23 | https://oehha.ca.gov/calenviroscreen/report/calenviroscreen-40 | Danielle Dolan | |

**ជំហានបន្ទាប់ និងការលើកពេល**

Rishiបានស្នើសុំយល់ព្រមការផ្អាក។ Melissa បានស្នើសុំ; Madeline បានស្នើសុំផងដែរ។ សមាជិកទាំងអស់ បោះឆ្នោតយល់ព្រម។ ផ្អាកនៅម៉ោង 8 យប់